# សង្ខេបលទ្ធផលកិច្ចប្រជុំរៀបចំផែនការ
# «ការវាយតម្លៃប្រព័ន្ធអេកូឡូស៊ីព្រៃឈើ បរិយាកាស និងអត្ថប្រយោជន៍នៃការអនុវត្តគម្រោងរេដបូកនៅកម្ពុជា»

សណ្ឋាគារឡឺរ៉ូយ៉ាល់, ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤

*កិច្ចប្រជុំរៀបចំផែនការនេះបានចាប់ផ្តើមដោយ*

<u>មតិចាប់អារម្មណ៍ក្នុងពិធីបើកកិច្ចប្រជុំ របស់ឯកឧត្តម ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ</u>

ដែលឯកឧត្តមបានផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើ៖

- តម្លៃ និងផលប្រយោជន៍ព្រៃឈើ និងសេវាជាច្រើនដែលជាច្រើនដែលយើងមិនដឹងពីតម្លៃពិត
- បានផ្តល់ឧទាហរណ៍ជាក់ស្តែងនៅប៉ៃលិនពាក់ព័ន្ធនឹងមុខងារព្រៃឈើក្នុងការជួយឲ្យមានលំនឹងបរិយាកាស
- តម្លៃព្រៃឈើនៅតំបន់ជួរភ្នំក្រវាញ និងព្រៃឡង់ពាក់ព័ន្ធនឹងតម្លៃនៃការអភិរក្សជីវៈចម្រុះ និងរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ី
- មុខងាររបស់ព្រៃឈើក្នុងការកាត់បន្ថយការហូរច្រោះនិងគ្រោះទឹកជំនន់ដោយសារលំហូរដ៏គំហុកពីតំបន់ខ្ពស់
- តម្លៃនៃព្រៃឈើដែលបាត់បង់ទៅ ទើបយើងគ្រប់គ្នាបានដឹងពីតម្លៃទាំងនេះ និងការលំបាក ក្នុងការស្តារព្រៃឈើទាំងនេះមកវិញ នៅពេលដែលព្រៃឈើ យើងបានបាត់បង់ទៅ
- យុទ្ធសាស្រ្តអភិរក្សជីវចម្រុះដោយគិតគូរពីច្រកតភ្ជាប់ពីតំបន់អភិរក្សមួយទៅតំបន់មួយទៀត
- ការសម្រេចចិត្តត្រូវការព័ត៌មានពីអ្នកបច្ចេកទេស ដើម្បីឲ្យការសម្រេចចិត្តធ្វើបានត្រឹមត្រូវ
- ដូច្នេះសកម្មភាពវាយតម្លៃព្រៃឈើនេះនឹងជួយឲ្យយើង បានយល់ដឹងច្បាស់ពីតម្លៃព្រៃឈើរបស់យើង
- ចុងបញ្ចប់ឯកឧត្តមបានវាយតម្លៃខ្ពស់សកម្មភាពដែលយើងរៀបចំផែនការនៅថ្ងៃនេះ ដូច្នេះឯកឧត្តមបានផ្តាំផ្ញើឲ្យកិច្ចប្រជុំ យកចិត្តទុកដាក់ពិភាក្សា និងចូលរួម ដើម្បីឲ្យបានលទ្ធផលល្អ។

*កិច្ចប្រជុំបានបន្តដោយ*

<u>បទបង្ហាញស្តីពីបរិបទ និងទិដ្ឋភាពរួមនៃសកម្មភាព ដោយលោកយុន វឌ្ឍនា ប្រធានលេខាធិការដ្ឋាន</u>

ដែលមានខ្លឹមសារផ្តោតសំខាន់លើ៖

- ការយល់ពីតម្លៃព្រៃឈើខុសៗគ្នា និងនៅមានកំរិត
- ការសិក្សានេះនឹងជួយដល់យើងបានយល់បានទូលំទូលាយពីគុណតម្លៃព្រៃឈើ
- រេដបូកអាចផ្តល់ការលើកទឹកចិត្តវិជ្ជមានដើម្បីការពារនិងប្រើប្រាស់ព្រៃឈើឲ្យបានប្រសើរជាងមុន
- ប៉ុន្តែតម្លៃនៃព្រៃឈើមានច្រើនជាងតម្លៃនៃការលើកទឹកចិត្តដែលបានពីរេដបូក
- ដូច្នេះអ្នកធ្វើសេចក្តីសម្រេចត្រូវមានទស្សនៈរួមអំពីថ្លៃចំណាយ និងផលចំណេញ ដើម្បីសម្រេចបាន

ត្រឹមត្រូវ

- ចុងបញ្ចប់លោកបញ្ជាក់ថាបទបង្ហាញបន្តនឹងផ្តល់ឲ្យយើងបានយល់កាន់តែស៊ីជម្រៅជាងនេះ។

*និងកិច្ចប្រជុំបានបន្តដោយ*

<u>លោកថូម៉ាស់ជាអ្នកសម្របសម្រួលកម្មវិធីUNEPប្រចាំតំបន់ បង្ហាញផែនការការងារពាក់ព័ន្ធនឹងសកម្មភាពនេះ</u>

ដែលមានខ្លឹមសារផ្តោតសំខាន់លើះ

- គោលបំណង និងសារសំខាន់នៃកិច្ចប្រជុំរៀបចំផែនការថ្ងៃនេះ
- កិច្ចប្រជុំថ្ងៃនេះជាសកម្មភាពមួយនៃកម្មវិធីUN-REDD
- ការវិភាគចំណាយ និងផលប្រយោជន៍ ជាការរួមវិភាគទានសំខាន់ដល់ការសម្រេចចិត្ត
- កិច្ចការងារដែលត្រូវធ្វើបន្តក្នុងកិច្ចប្រជុំរៀបចំផែនការ
- កិច្ចការងារដែលយើងនឹងបន្តធ្វើក្រោយពីកិច្ចប្រជុំ
- ជោគជ័យនៃការងារនេះអាស្រ័យលើការប្តេជ្ញា និងការចូលរួមរបស់យើងទាំងអស់គ្នា

*និងកិច្ចប្រជុំបានបន្តដោយ*

<u>បទបង្ហាញស្តីពីតួនាទីនៃសេដ្ឋកិច្ចក្នុងការកសាងផែនការរេដបូករបស់លោកវ៉ាល់ បែនលី ជាអ្នកឯកទេស WCMC-UNEP</u>

ដែលមានខ្លឹមសារផ្តោតសំខាន់លើះ

- ហេតុផលនៃការរួមបញ្ចូលពហុប្រយោជន៍នៅក្នុងការកសាងផែនការសម្រាប់រេដបូក
- ការវិភាគសេដ្ឋកិច្ចនៃរេដបូក ត្រូវមានសមត្ថភាពប្រមូល វិភាគទិន្នន័យ និងវិភាគឯកសារនានា ដែលមានស្រាប់
- កំណត់ទិន្នន័យ និងព័ត៌មានដែលនៅខ្វះចន្លោះ និង សំណួរនានាវិភាគសេដ្ឋកិច្ច
- ការគិតគូរអំពីជម្រើស ក្នុងករណីមាន ឬ គ្មាន រេដបូក និង
- ប៉ាន់ប្រមាណការប្រែប្រួលស្ថានភាពក្នុងករណីដែលគ្មានរេដបូក និងផលប៉ះពាល់
- គណនា និងវិភាគថ្លៃចំណាយ និងផលចំណេញ និងកម្រិតល្អៀងនៃតួលេខប៉ាន់ស្មាន
- គិតគូរពីចំណាយ និងផលចំណេញ សម្រាប់អ្នកពាក់ព័ន្ធដូចជាះ បុគ្គល រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត
- ចុងបញ្ចប់លោកសន្និដ្ឋានថាះ ការវិភាគសេដ្ឋកិច្ចសម្រាប់រេដបូកជាតម្រូវការចាំបាច់ ប៉ុន្តែការវិភាគនេះគ្រាន់តែជាធាតុមួយនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តប៉ុណ្ណោះ។

*និងកិច្ចប្រជុំបានបន្តដោយសំណួរចម្លើយ*

- លោក ថូម៉ាស់ បានផ្តល់ព័ត៌មាន ពីតម្លៃកាបូនដែលបានលក់នៅបណ្តាប្រទេសនានា
- ឯកឧត្តម ជា សំអាងះ បានទាញការចាប់អារម្មណ៍ថាះ គួរផ្តោតលើយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើឲ្យបាន

ល្អ ជាជាងការចាប់អារម្មណ៍លើតម្លៃកាបូន ព្រោះថាព្រៃឈើមានតម្លៃច្រើនលើសលប់ជាងតម្លៃកាបូន។ ចំណូលដែលបានពីកាបូន គ្រាន់តែជាតម្លៃបន្ថែមប៉ុណ្ណោះ។

- លោក ឡេង ជីវិន (FA)៖ ការបាត់បង់ព្រៃឈើកំពុងកើតមាន តើរេដបូកត្រូវមានយុទ្ធសាស្ត្រ ឬ គោលនយោបាយយ៉ាងណា ដើម្បីការពារព្រៃឈើឲ្យបានទាន់ពេលវេលា?
- លោក យុន វឌ្ឍនា (RTS)៖ ក្រុមការងារបាននឹងកំពុងរៀបចំយុទ្ធសាស្ត្ររេដបូក សេចក្តីព្រាងយុទ្ធសាស្ត្រនេះ នឹងយកទៅបង្ហាញនៅ COP 21 Paris 2015 ។
- លោក ឡេង ជីវិន (FA)៖ តើត្រូវរង់ចាំរហូតដល់យុទ្ធសាស្ត្រ ឬ គោលនយោបាយរេដបូក បានរៀបចំរួចរាល់ទើបមានសកម្មាពឆ្លើយតបនិងការបាត់បង់និងការពារព្រៃឈើ?
- លោក យុន វឌ្ឍនា (RTS)៖ ជាបណ្តើរៗ សកម្មភាពឆ្លើយតបនឹងការបាត់បង់ព្រៃឈើនៅទីវាល បានធ្វើឡើងតាមរយៈការគាំទ្រទៅគម្រោងសាកល្បង នៅឧត្តរមានជ័យនិងសីម៉ា ដោយសារថវិកាគម្រោងបានផ្តោតសំខាន់លើការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ។ សង្ឃឹមថានៅពេលមានយុទ្ធសាស្ត្រ ឬ គោលនយោបាយរេដបូក យើងអាចទទួលបានថវិកាច្រើន ដើម្បីអនុវត្តសកម្មភាពនៅទីវាល ឧទាហរណ៍ដូចជាប្រទេសវៀតណាម។
- លោក សេង បូរ៉ា (CI)៖ លោកយល់ថារេដជាគ្រាន់តែជាផ្នែកមួយនៃការគ្រប់គ្រងព្រៃឈើប៉ុណ្ណោះ។ លោកបានបញ្ជាក់បន្ថែម ថាកន្លងមករដ្ឋាភិបាលបានសហការជាមួយ អង្គការនានាដូចជា៖ CI, WCS, WWF ដើម្បីទប់ស្កាត់បទល្មើសនៅទីវាល។ ជាក់ស្តែង អង្គការ CI បានសហការជាមួយរដ្ឋាភិបាលអនុវត្តសកម្មភាពអភិរក្សនៅតំបន់ភ្នំក្រវាញដើម្បីទប់ស្កាត់បទល្មើស។ លោកសំណូមពរថាសូមឲ្យរដ្ឋាភិបាលបន្តជួយគាំទ្របន្តទៀត។
- លោក ភីធ័រ៖ បានសូមឲ្យបញ្ជាក់ពីការបង្កើនការងាររបស់រេដបូក និងបរិមាណនៃការងាររេដបូក។
- លោក វ៉ាល់ បែនលី៖ បានបញ្ជាក់ថាការងារដែលពាក់ព័ន្ធនឹងរេដបូក មាន២ប្រភេទ គឺការងារដែលបានបាត់បង់ទៅដោយសាររេដបូក ដូចជាការងារធ្វើអាជីវកម្មព្រៃឈើ និងការងារដែលបានបង្កើតឡើយដោយ រេដបូកដូចជាការរៀបចំឲ្យមានសកម្មភាពទ្រទ្រង់ជីវភាពរស់នៅរបស់សហគមន៍តាមរយៈរេដបូក។

*និងកិច្ចប្រជុំបានបន្តដោយ*

<u>បទបង្ហាញស្តីពីការវាយតម្លៃអេកូឡូស៊ីព្រៃឈើនៅកម្ពុជារបស់លោកបណ្ឌិត អ៊ុំ រតនៈទីប្រឹក្សាឯករាជ្យ</u>

ដែលមានខ្លឹមសារផ្តោតសំខាន់លើ៖

- តម្លៃប៉ាន់ស្មាននៃផលិតផលព្រៃឈើ និងអនុផលព្រៃឈើ
- តម្លៃប៉ាន់ស្មាននៃទេសចរណ៍ ការកំសាន្ត ជីវៈចម្រុះ វប្បធម៌ និងជំនឿ
- តម្លៃនៃការបំពេញមុខងារដូចជា៖ ចម្រោះទឹក ខួបនៃការផ្តល់ជីរជាតិការបន្តពូជដោយលំអង និងបង្កាសត្វចង្រៃ
- តម្លៃប៉ាន់ស្មាននៃការស្រូបយកកាបូន
- តម្លៃប៉ាន់ស្មាននៃការការពារទីជម្រាល ការហូរច្រោះ និងការពារព្យុះ
- តម្លៃប៉ាន់ស្មាននៃជម្រើសនៃការប្រើប្រាស់

- តម្លៃអត្ថិភាព និងតម្លៃអច្ច័យទាន

*និងកិច្ចប្រជុំបានបន្តដោយ*

<u>បទបង្ហាញស្តីពីបទពិសោធន៍អន្តរជាតិនៃការវាយតម្លៃប្រព័ន្ធអេកូឡូស៊ីព្រៃឈើរបស់លោកលោកវ៉ាល់ បែនលី ជាអ្នកឯកទេស WCMC-UNEP</u>

ដែលមានខ្លឹមសារផ្តោតសំខាន់លើ៖

- ប្រវត្តិនៃការវាយតម្លៃព្រៃឈើដូចជា៖
    - ការគ្រប់គ្រង និងការកសាងផែនការព្រៃឈើ
    - ការទទួលស្គាល់អំពីតម្លៃនៃការសម្រាកកំសាន្ត ជីវៈចម្រុះ និងការបង់ថ្លៃសេវាប្រព័ន្ធអេកូឡូស៊ី
- ប្រវត្តិនៃការវាយតម្លៃព្រៃឈើពាក់ព័ន្ធនឹងរេដបូកដូចជា៖
    - ការពិនិត្យឯកសារនានានៅក្នុងការសិក្សាអំពីការវាយតម្លៃសេដ្ឋកិច្ច
    - ការវិភាគតាមវិស័យអំពីផលប្រយោជន៍នៃព្រៃឈើ
    - របបចិញ្ចឹមជីវិតនៅមូលដ្ឋាន
    - ការកសាងផែនការពិស្តារ
    - ការធ្វើម៉ូដែលសេណារីយ៉ូថ្លៃចំណាយ-ផលចំណេញ
- ម៉ូដែល និងឧបករណ៍ដែលប្រើប្រាស់សម្រាប់វាយតម្លៃព្រៃឈើជាតម្លៃសេដ្ឋកិច្ច

*និងកិច្ចប្រជុំបានបន្តដោយ*

<u>បទបង្ហាញស្តីពីការចំណាយនិងអត្ថប្រយោជន៍នៃការអនុវត្តរេដបូករបស់លោកងួន ភក្តី អ្នកស្ម័គ្រចិត្តនៅលេខាធិការដ្ឋាន</u>

ដែលមានខ្លឹមសារផ្តោតសំខាន់លើ៖

- អត្ថប្រយោជន៍រេដបូកទាំងនៅថ្នាក់ជាតិ និងនៅមូលដ្ឋាន ទៅលើសេដ្ឋកិច្ច សង្គម និងបរិស្ថាន
- ដំណាក់កាលរេដបូកនិងសក្តានុពល ក្នុងការបង្កើតផលប្រយោជន៍
- ការចំណាយលើរេដបូកដូចជា៖
    - ឱកាស
    - ការអនុវត្តន៍
    - ការប្រតិបត្តិ
    - ស្ថាប័ន
- យុទ្ធសាស្ត្រដើម្បីកាត់បន្ថយការចំណាយ
- ចុងបញ្ចប់ការសន្និដ្ឋានក្នុងការអនុវត្តរេដបូកឲ្យមានប្រសិទ្ធិភាពលើការចំណាយ

*បន្ទាប់ពីសម្រាក ដើម្បីទទួលទានអាហារថ្ងៃត្រង់អង្គសិក្ខាសាលាបានបន្តឲ្យមាន*

<u>ការចែកក្រុមពិភាក្សាជា០២ក្រុមដោយមានអ្នកសម្របសម្រួលចំនួន០២រូបគឺ លោកអ៊ុំ រតនៈ និងលោកងួន ភក្តី</u>

ការពិភាក្សាចែកជា២ផ្នែក គឺការលើកឡើងពីសំណួរ ឬ បញ្ហា និងដំណោះស្រាយដើម្បីឲ្យកម្ពុជាអាចសម្រេចដំណាក់កាលទី១ គឺការត្រៀមលក្ខណៈអនុវត្តរេដបូក។

<u>លទ្ធផល ពិភាក្សារបស់ក្រុមលោក ងួន ភក្តី និង លន់ គឹមហ៊ី</u>

1. តើមានសង្ឃឹមថាបានជោគជ័យកំរិតណាក្នុងការអនុវត្តរេដបូក?(សិក្សាបន្ត)
2. តើមានភស្តុតាងអ្វីខ្លះបញ្ជាក់ថារេដបូកបានជោគជ័យ?(សិក្សាបន្ត)
3. ការសិក្សាត្រូវមានភាពសុក្រិត្យដោយគ្មានលំអៀងដើម្បីបានដឹងថា តើការលក់កាបូន ឬ ការលក់ឈើណាមួយមានប្រយោជន៍ជាង? (សិក្សាបន្ត)
4. តើត្រូវមានការសិក្សា និងត្រួតពិនិត្យលើការប្រើប្រាស់ព្រៃឈើរបស់អ្នកពាក់ព័ន្ធដោយរបៀបណាដើម្បីកុំឲ្យការអនុវត្តរេដបូកមានផលប៉ះពាល់ជាអវិជ្ជមាន?(សិក្សាបន្ត)
5. តើគួរទប់ស្កាត់បទល្មើសព្រៃឈើ ដែលប្រព្រឹត្តដោយអ្នកខាងក្រៅតាមវិធីសាស្ត្រណា? (បង្កើនការផ្សព្វផ្សាយ និងសមត្ថភាពរបស់ក្រុមល្បាត ឧទាហរណ៍: មធ្យោបាយ ឧបករណ៍ សម្ភារៈ ថវិកា ។ល។)
6. តើយន្តការដោះស្រាយទំនាស់ត្រូវផ្អែកលើមូលដ្ឋានច្បាប់ឬ ការសម្របសម្រួល? (ដោះស្រាយទៅតាមប្រភេទ និងកម្រិតនៃទំនាស់ ឧទាហរណ៍ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការសម្រាប់សហគមន៍)
7. តើផលដែលទទួលបានពីរេដបូកនឹងត្រូវបែងចែកដោយរបៀបណា? (សមភាពក្នុងការបែងចែកផលប្រយោជន៍)
8. តើអ្នកណាជាអ្នកទិញកាបូនពីគម្រោងរេដបូក? (COP ត្រូវជំរុញ(បង្ខំ)ឲ្យប្រទេសអភិវឌ្ឍន៍បង្កើតច្បាប់សកល ដើម្បីធានាការទិញកាបូនពីប្រទេសអនុវត្តគម្រោង)

<u>លទ្ធផល ពិភាក្សារបស់ក្រុមលោក អ៊ុំ រតន:</u>

១. តើហេតុអ្វីបានជាត្រូវការសិក្សាពីតម្លៃនៃប្រព័ន្ធអេកូឡូស៊ីព្រៃឈើ?
២. តើប្រព័ន្ធអេកូឡូស៊ីព្រៃឈើ និងរេដបូក មានភាពទាក់ទងជាមួយគ្នាយ៉ាងដូចម្តេច?
៣. តើទិន្នន័យនៃការវាយតម្លៃ គួរត្រូវបានធ្វើបច្ចុប្បន្នកម្មយ៉ាងញឹកញាប់ដោយរបៀបណា?
៤. តើមានផលប្រយោជន៍យ៉ាងដូចម្តេចខ្លះក្នុងការអនុវត្តរេដបូក/មិនអនុវត្តន៍រេដបូក?
៥. តើមានការចំណាយ និងចំណេញអ្វីខ្លះនៅពេលអនុវត្តន៍រេដបូកនៅកម្ពុជា?

1. Why do we need to estimate the values of forest ecosystem services?
2. What are the relation between forest ecosystem valuation and REDD+?
3. How often should we update the valuation data?
4. What are the benefits with REDD+ /without REDD+ implementation?
5. What are the costs and benefits when implementing REDD+ in Cambodia?

*សេចក្តីសង្ខេបលទ្ធផលសិក្ខាសាលាសូមបញ្ចប់ និងសូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់។*